ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០១ សហវ.ប្រកប

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ ២០១៤

# សេចក្តីជូនដំណឹង

## ជម្រាបមក

## លោកនាយក/លោកស្រីនាយិកាក្រុមហ៊ុនកាស៊ីណូទាំងអស់

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់លោកនាយក/ លោកស្រីនាយិកាក្រុមហ៊ុនកាស៊ីណូទាំងអស់ ដែលបាននិងកំពុងធ្វើអាជីវកម្មឲ្យបានជ្រាបថា កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសង្កេតឃើញថា មានក្រុមហ៊ុនកាស៊ីណូមួយចំនួនតែងតែស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាំចូលឧបករណ៍ ឬសម្ភារៈល្បែងកាស៊ីណូជាបន្តបន្ទាប់ យកទៅជំនួសឧបករណ៍ ឬ សម្ភារៈល្បែងចាស់ៗខូចគុណភាព ។

ដើម្បីឈានទៅបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងឧបករណ៍ ឬសម្ភារៈល្បែងកាស៊ីណូ សំដៅក្តាប់ឲ្យបានអំពីចំនួនសរុបនៃតុល្បែង ទូល្បែង និងប្រភេទល្បែង ព្រមទាំងសម្ភារៈល្បែងឲ្យបានច្បាស់លាស់ ក៏ដូចជាទប់ស្កាត់ឲ្យបាននូវរាល់ការចល័តឧបករណ៍ ឬ សម្ភារៈល្បែងពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម ÷

១- ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ការស្នើសុំនាំចូលឧបករណ៍ ឬ សម្ភារៈល្បែង ក្រុមហ៊ុនកាស៊ីណូនីមួយៗត្រូវកំណត់កម្មវិធីស្នើសុំនាំចូលឧបករណ៍ ឬ សម្ភារៈល្បែងប្រចាំឆ្នាំរបស់ខ្លួនឲ្យបានច្បាស់លាស់ ដោយភ្ជាប់មកជាមួយនូវចំនួនសរុបនៃតុល្បែង ទូល្បែង និងប្រភេទល្បែង ព្រមទាំងសម្ភារៈល្បែងដែលមាននៅក្នុងកាស៊ីណូ និងអាជ្ញាប័ណ្ណធ្វើអាជីវកម្មកាស៊ីណូ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- មុននឹងអនុញ្ញាតឲ្យមានការនាំចូលឧបករណ៍ ឬសម្ភារៈល្បែងថ្មី ក្រសួងនឹងចាត់បញ្ជូនមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែង ។

៣- ក្នុងករណីមិនអនុវត្តតាមការណែនាំនេះ ក្រសួងនឹងមិនអនុញ្ញាតឲ្យមានការនាំចូលឧបករណ៍ ឬសម្ភារៈល្បែងថ្មីឡើយ ។

ទទួលបានសេចក្តីណែនាំនេះ សូមលោកនាយក/លោកស្រីនាយិកាក្រុមហ៊ុនកាស៊ីណូទាំងអស់ ខិតខំអនុវត្តតាមការណែនាំនេះ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧,៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com